01330993

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 09 / 2016
ម៉ោង (Time/Heure) : 13:41
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E389/5/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** ដីកាកំណត់ពេលវេលាធ្វើតេស្តនៅលើបញ្ហាស្មារតីរបស់ជនជាប់ចោទ

១. នៅថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចស្តីពីសម្បទារបស់ជនជាប់ចោទនីមួយៗក្នុងការចូលរួមសវនាការ រួមជាមួយនឹងការបង្គាប់ឱ្យធ្វើតេស្តទៅលើមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទម្នាក់ៗប្រចាំត្រីមាស (ឯកសារ E389/5 សម្រាប់ នួន ជា, ឯកសារ E389/6 សម្រាប់ ខៀវ សំផន)។ នៅក្នុងសេចក្តីសម្រេចទាំងពីរនេះ អង្គជំនុំជម្រះបានបង្គាប់ឱ្យបន្តការធ្វើតេស្តលើមុខងារបញ្ញាស្មារតីរបស់ជនជាប់ចោទជារៀងរាល់ត្រីមាស ដោយប្រើប្រាស់តេស្តមួយដែលបង្កើតឡើងដោយអ្នកជំនាញ និង យកទៅអនុវត្តដោយគ្រូពេទ្យវេជ្ជសាស្ត្រ ដែលបានចុះកិច្ចសន្យាផ្តល់សេវាជូនមន្ទីរឃុំឃាំង អ.វ.ត.ក ("អង្គភាពពេទ្យ") (ឯកសារ E389/5 កថាខណ្ឌ ១៣, ឯកសារ E389/6 កថាខណ្ឌ ១៣)។ អង្គជំនុំជម្រះបានចាត់តាំងវេជ្ជបណ្ឌិត CHAN Kin Ming និង វេជ្ជបណ្ឌិត ហួត លីនណា ជាអ្នកជំនាញដែលត្រូវរៀបចំតេស្តលើបញ្ហាស្មារតីរបស់ជនជាប់ចោទ និងធ្វើការជាមួយបុគ្គលិក

អង្គភាពពេទ្យ ដើម្បីធានាឱ្យមានការអនុវត្តតេស្តទាំងនេះបានត្រឹមត្រូវ ដោយចាប់ផ្តើមអនុវត្តតេស្តដំបូង មិនឱ្យហួសពីថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១៦ ឡើយ (ឯកសារ E389/5 ផ្នែកសម្រេចសេចក្តី, ឯកសារ E389/6 ផ្នែកសម្រេចសេចក្តី)។

២. ការធ្វើតេស្តត្រួសៗលើមុខងារបញ្ញាស្មារតី (ការធ្វើតេស្ត AMT) ថ្មីដែលបង្កើតឡើងដោយអ្នកជំនាញ ត្រូវបានយកទៅអនុវត្តលើជនជាប់ចោទនីមួយៗ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦ ដោយវេជ្ជបណ្ឌិតនៃអង្គភាពពេទ្យ គឺសាស្ត្រាចារ្យ ចក ធីតា និងវេជ្ជបណ្ឌិត ឈួរ ចាន់ណារា។ អង្គជំនុំជម្រះយល់ឃើញថា ជាការសមស្របដែលវេជ្ជបណ្ឌិតទាំងពីររូបនេះ ត្រូវអនុវត្តតេស្តនាពេលខាងមុខទៀតរួមគ្នាផងដែរ។ អង្គជំនុំជម្រះបង្គាប់ឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ជួយសម្របសម្រួល និង កំណត់កាលបរិច្ឆេទសម្រាប់ការធ្វើតេស្តប្រចាំត្រីមាស បីលើកបន្តបន្ទាប់ទៀត នៅក្នុងអំឡុងពេលដូចខាងក្រោម៖

- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦
- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៧ និង
- ចន្លោះពីថ្ងៃទី ០១ ដល់ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៧

៣. អង្គជំនុំជម្រះក៏បង្គាប់ឱ្យអង្គភាពពេទ្យដាក់ជូនអង្គជំនុំជម្រះសាលាដំបូងនូវលទ្ធផលនៃការធ្វើតេស្ត AMT ទៅលើជនជាប់ចោទនីមួយៗ ឱ្យបានឆាប់តាមដែលអាចធ្វើបាន បន្ទាប់ពីការធ្វើតេស្តនីមួយៗបានបញ្ចប់នោះ។